ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

********

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រ.គ លេខ ០៩.០០៦/០៩ គជប.អគ្គ.ពស

ភ្នំពេញ ថ្ងៃទី 15 ខែកញ្ញា ឆ្នាំ២០០៩

# វគ្គបណ្តុះបណ្តាលស្តីពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០០៩

វគ្គបណ្តុះបណ្តាលស្តីពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០០៩ ដែលបានប្រព្រឹត្តទៅពេញមួយថ្ងៃ បានបញ្ចប់នៅរសៀលថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៩ ក្រោមអធិបតីភាពឯកឧត្តម អ៊ឹម សូស៊ី ប្រធាន គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត( គ.ជ.ប ) ។

សិក្ខាកាមចូលរួមជាមន្ត្រីមកពីលេខាធិការដ្ឋានរាជធានី/ខេត្តរៀបចំការបោះឆ្នោត( លធ/ខប ) មន្ត្រីនៅទីស្តីការ គ.ជ.ប តំណាងគណបក្សប្រជាជនកម្ពុជា គណបក្សសម រង្ស៊ី គណបក្សសិទ្ធិមនុស្ស គណបក្សចលនាប្រជាធិតេយ្យ គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ តំណាងអង្គការខុមហ្វ្រែល និចហ្វិក NDI អង្គការអភិវឌ្ឍន៍សង្គម អង្គការអរុណរះ និងអង្គការពន្លឺអភិវឌ្ឍន៍ជនក្រីក្រ សរុបប្រមាណ ៩០ នាក់ ។

ឯកឧត្តម អ៊ឹម សូស៊ី បានមានមតិណែនាំថា សិក្ខាកាមទាំងអស់ត្រូវពិនិត្យមើលឯកសារដែលបានចែកជូនឱ្យបានច្បាស់ ព្រោះការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំនេះគឺដំណើរការដូចឆ្នាំមុនៗដែរ វាមិនមានអ្វីប្រែប្រួលច្រើនទោះទេ ។ ឯកឧត្តមបានបញ្ជាក់ថា ចំណុចថ្មីដែលត្រូវអនុវត្តនោះគឺទាក់ទងនឹងបណ្តឹងដែលកន្លងមកអ្នកកើតមានបញ្ហាបានផ្ទេរសិទ្ធិទៅឱ្យអ្នកមួយទៀតហើយខ្លួនឯង( អ្នកកើតមានបញ្ហា ) បែរមកធ្វើជាសាក្សី នៅពេលសួរហេតុផលទៅដើមបណ្តឹង ដែលត្រូវបានផ្ទេរសិទ្ធិនោះគាត់ពុំដឹងអ្វីទាំងអស់ បែរជាឱ្យសួរទៅសាក្សីនាំឱ្យច្របូកច្របល់ និងមានការលំបាក ។ លើកនេះ គ.ជ.ប អនុវត្តនីតិវិធីធ្វើដូចនីតិវិធីរបស់តុលាការមិនអនុញ្ញាតឱ្យអ្នកកើតមានបញ្ហា ឬដើមបណ្តឹងដែលបានផ្ទេរសិទ្ធិជូននរណាម្នាក់មិនអាចធ្វើជាសាក្សីបានឡើយ ។ ឯកឧត្តមបានបញ្ជាក់ទៀតថា លធ/ខប ត្រូវយកចិត្តទុកដាក់បង្រៀនស្មៀនឃុំ សង្កាត់ និងក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យធ្វើកំណត់ហេតុសាកសួរឱ្យបានច្បាស់លាស់ក្នុងករណីកើតមានបណ្តឹង ជៀសវាងការសម្រេចអ្វីមួយដោយមិនមានព័ត៌មានច្បាស់ ។ ជាពិសេសត្រូវជំរុញឱ្យស្មៀនសរសេរឈ្មោះអ្នកមកចុះឈ្មោះឱ្យបានច្បាស់លាស់ និងត្រូវប្រយ័ត្នប្រយែងជាងឆ្នាំមុនៗ ។ ឯកឧត្តមបានបន្ថែមថា ចំពោះការកែតម្រូវឈ្មោះ ធ្វើយ៉ាងណាឱ្យបានត្រូវតាមអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែលអ្នកសុំកែនោះមាន ហើយការធ្វើបែបនេះដើម្បីងាយស្រួល និងជៀសវាងការសុំបញ្ជាក់ទម្រង់ ១០១៨ ។

ជាមួយគ្នានេះដែរឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប បានធ្វើការអំពាវនាវតាមរយៈសារព័ត៌មាន សូមឱ្យបងប្អូនប្រជាពលរដ្ឋទាំងអស់ ជាពិសេសយុវជន យុវនារីដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ ពុំទាន់បានចុះឈ្មោះបោះឆ្នោត សូមអញ្ជើញទៅចុះឈ្មោះបោះឆ្នោត ចំពោះបងប្អូនប្រជាពលរដ្ឋដែលបានផ្លាស់ប្តូរទីលំនៅ ទៅឃុំ សង្កាត់ថ្មី សូមមេត្តាអញ្ជើញ

ទៅចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ថ្មី និងផ្តល់ព័ត៌មានដល់ស្មៀនឃុំ សង្កាត់ដើម្បីលុបឈ្មោះចេញពីបញ្ជីឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ចាស់ ជៀសវាងកុំឱ្យមានឈ្មោះស្ទួន និងបញ្ជីបោះឆ្នោតប៉ោង ។ ហើយចំពោះបងប្អូនប្រជាពលរដ្ឋមួយចំនួនមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដែលខុសអក្ខរាវិរុទ្ធ ឬមិនឡូវ័យ បើប្រៀបធៀបទៅនឹងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សូមអញ្ជើញរួសរាន់ទៅកែតម្រូវឈ្មោះឱ្យបានត្រឹមត្រូវព្រោះថាយើងមានឱកាសពីរឆ្នាំ គឺឆ្នាំ២០០៩ និង២០១០ ដើម្បីធ្វើការកែតម្រូវបញ្ជីបោះឆ្នោតឱ្យមានសុក្រិតភាព ហើយនៅឆ្នាំ២០១១ នឹងដំណើរការចុះឈ្មោះដើម្បីបោះឆ្នោត ។

តាមតារាងស្ថិតិប្រជាពលរដ្ឋប៉ាន់ស្មាន អ្នកដែលត្រូវចុះឈ្មោះបោះឆ្នោតក្នុងឆ្នាំនេះមានចំនួន ៣៥១.៨៦២ នាក់ ។ ហើយការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត នឹងចាប់ផ្តើមពីថ្ងៃទី១ ខែតុលា ដល់ថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩ នៅតាមសាលាឃុំ សង្កាត់ ទូទាំងប្រទេស ។

ព័ត៌មានបន្ថែម សូមទំនាក់ទំនងផ្នែកព័ត៌មាន ទូរស័ព្ទលេខ៖ 023 214 231 / 012 855 018 & Fax 023 214 374